# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤

## ការប្រគល់ជូនគ្រឿងឥស្សរិយយសព្រះចៅអធិរាជជប៉ុន
## (The Order of the Rising Sun, Gold Rays with Rosette)
## ចំពោះ លោក គង់ ថន ប្រធានក្រុមប្រឹក្សាភិបាល
## នៃអនុនិងវិទ្យាល័យមិត្តភាពកម្ពុជា-ជប៉ុនខេត្តព្រៃវែង
## និងជាប្រធានអង្គការមូលនិធិខ្មែរជំនួយការសិក្សា (CEAF)

នៅ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤ រដ្ឋាភិបាលជប៉ុនបានប្រកាសជាផ្លូវការនូវឈ្មោះជនបរទេសដែលជាអ្នកទទួលបានគ្រឿងឥស្សរិយយសព្រះចៅអធិរាជជប៉ុនប្រចាំនៅសរទរដូវឆ្នាំ២០១៤។ ក្នុងចំនោមអ្នកទទួលដែលជាជនបរទេសចំនួន៥៧នាក់ លោក **គង់ ថន** ប្រធានក្រុមប្រឹក្សាភិបាលនៃអនុនិងវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុន ខេត្តព្រៃវែង និងជាប្រធានអង្គការមូលនិធិខ្មែរជំនួយការសិក្សានៅកម្ពុជា (CEAF) បានទទួលនូវគ្រឿងឥស្សរិយយសព្រះចៅអធិរាជជប៉ុនមេជាយប្រភេទ The Order of the Rising Sun, Gold Rays with Rosette ជាការទទួលស្គាល់នូវការចូលរួមចំណែកដ៏ធំធេងដល់ការអភិវឌ្ឍន៍ការអប់រំភាសាជប៉ុននៅប្រទេសកម្ពុជា និងការជម្រុញការយល់ដឹងអំពីគ្នាទៅវិញទៅមករវាងប្រទេសជប៉ុននិងប្រទេសកម្ពុជា។

- គ្រឿងឥស្សរិយយស: គ្រឿងឥស្សរិយយសព្រះចៅអធិរាជជប៉ុន (The Order of the Rising Sun, Gold Rays with Rosette)
- បរិចារកិច្ច: ចូលរួមចំណែកលើការអភិវឌ្ឍន៍ការអប់រំភាសាជប៉ុននៅប្រទេសកម្ពុជា និងការជម្រុញការយល់ដឹងអំពីគ្នាទៅវិញទៅមករវាងប្រទេសជប៉ុននិងកម្ពុជា។
- ឈ្មោះអ្នកទទួល (អាយុ): **គង់ ថន** (៧៧ឆ្នាំ)
- មុខតំណែងសំខាន់ៗ:
  - ប្រធានក្រុមប្រឹក្សាភិបាលនៃអនុនិងវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុនខេត្តព្រៃវែង
  - ប្រធានប្រធានអង្គការមូលនិធិខ្មែរជំនួយការសិក្សានៅកម្ពុជា (CEAF)

- អាស័យដ្ឋាន (សញ្ជាតិ): ផ្ទះលេខ២១E០ , ផ្លូវ៤៩៦, សង្កាត់ផ្សារដើមថ្កូវ, ខណ្ឌចំការមន, ភ្នំពេញ (សញ្ជាតិកម្ពុជា)

លោក **គង់ វាន** បានបំរើការឱ្យសារព័ត៌មានជប៉ុននៅក្នុងប្រទេសកម្ពុជាពីកំឡុងឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥។ បន្ទាប់ពីបានឆ្លងកាត់ភាពលំបាកនៃការងារពលកម្មដោយការបង្ខិតបង្ខំរយៈពេលជាង៤ឆ្នាំក្នុងកំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) លោកបានភៀសខ្លួនទៅកាន់ប្រទេសជប៉ុន និងបានរស់នៅទីនោះក្នុងនាមជាជនភៀសខ្លួននយោបាយក្នុងឆ្នាំ១៩៨១។ លោកបានបង្កើតមូលនិធិខ្មែរជំនួយការសិក្សា (CEAF) នៅប្រទេសជប៉ុនក្នុងឆ្នាំ១៩៩៣ និងចាប់ផ្តើមធ្វើជាប្រធានអង្គការមូលនិធិដោយបានសាងសង់សាលារៀនចំនួន៥នៅក្នុងប្រទេសកម្ពុជាជាបន្តបន្ទាប់។ លោកបានបង្កើតនូវសមិទ្ធិផលដ៏អស្ចារ្យក្នុងកិច្ចការកែលម្អប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជា តាមរយៈការនៃនាំឱ្យមាននូវប្រព័ន្ធសិក្សាតាមបែបប្រទេសជប៉ុន និងការបង្រៀនភាសាជប៉ុនក៏ដូចជាការផ្សព្វផ្សាយអំពីកេរ្តិ៍ឈ្មោះនៃប្រទេសជប៉ុននិងប្រព័ន្ធសិក្សាប្រទេសជប៉ុននៅក្នុងប្រទេសកម្ពុជាផងដែរ។

ក្នុងឆ្នាំ១៩៩៩ លោក **គង់ វាន** បានសាងសង់អនុនិងវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុន ខេត្តព្រៃវែងលើដីរបស់គាត់មួយកន្លែងជិត៣.៧១ហិកតានិងបានចាប់ផ្តើមធ្វើជាប្រធានក្រុមប្រឹក្សាភិបាលរបស់វិទ្យាល័យ។ លោកបានអញ្ជើញគ្រូស្ម័គ្រចិត្តភាសាជប៉ុនពីប្រទេសជប៉ុន និងបានចូលរួមចំណែកលើកកម្ពស់ការសិក្សាភាសាជប៉ុននៅ ស្រុកព្រះស្តេច ក្នុងខេត្តព្រៃវែង។ អនុនិងវិទ្យាល័យមួយនេះមួយនេះគឺជាសាលារៀនតែមួយគត់នៅក្នុងប្រទេសកម្ពុជាដែលមានកាលវិភាគការបង្រៀនភាសាជប៉ុន នៅក្នុងថ្នាក់នៃកំរិតអនុវិទ្យាល័យនិងវិទ្យាល័យ ហើយចំនួនយុវជនខ្មែរដែលនិយាយភាសាជប៉ុនត្រូវបានបង្កើតឡើងតាមរយៈអនុនិងវិទ្យាល័យមួយនេះជារៀងរាល់ឆ្នាំ។

លោក **គង់ វាន** កោតសរសើរចំពោះប្រព័ន្ធអប់រំប្រទេសជប៉ុនដែលជំរុញឱ្យលោកពាំនាំនូវចំនុចល្អៗទាំងនេះ មកអនុវត្តក្នុងការអប់រំនៅនៃអនុវិទ្យាល័យនិងវិទ្យាល័យមិត្តភាពកម្ពុជា-ជប៉ុនមួយនេះ។ លោកបានពង្រីកនូវការគោរពក្នុងចំណោមប្រជាជនកម្ពុជាចំពោះប្រទេសជប៉ុននិងប្រជាជនជប៉ុន និងបង្ហាញនូវកេរ្តិ៍ឈ្មោះនៃប្រព័ន្ធអប់រំប្រទេសជប៉ុនឱ្យបានទូលំទូលាយនៅក្នុងប្រទេសកម្ពុជាតាមរយៈសកម្មភាពជាច្រើន។

លោក **គង់ វាន** ក៏បានបង្កើតឱ្យមាននូវកម្មវិធីបំលាស់ប្តូរយុវជនរវាងកម្ពុជានិងជប៉ុននិងបានដើរតួនាទីដ៏សំខាន់ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីគ្នាទៅវិញទៅមក និងចំណងមិត្តភាពរវាងប្រទេសទាំងពីរ។

លោក **គង់ វាន** បានធ្វើការឱ្យសារព័ត៌មានជប៉ុនពីកំឡុងឆ្នាំ១៩៧០ដល់១៩៧៥និងបានធ្វើរបាយការណ៍ដ៏ទាន់ហេតុការណ៍និងជាក់លាក់អំពីស្ថានភាពឥណ្ឌូចិន នាពេលនោះ

ជូនប្រជាជនជប៉ុន។ លោកក៏បានបោះពុម្ពសៀវភៅដែលបកស្រាយអំពីបទពិសោធន៍របស់លោក ក្នុងកំឡុងសម័យកម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា “ការគេចផុតពីវាលពិឃាត” ហើយបន្ទាប់ពីនោះលោកក៏បានចូលរួមចំណែកដ៏ធំធេងក្នុងការលើកកម្ពស់ការសិក្សាអំពីប្រវត្តិសាស្ត្រសម័យទំនើបនៃប្រទេសកម្ពុជាក្នុងចំនោមអ្នកប្រវត្តិសាស្ត្រ និងអ្នកស្រាវជ្រាវជនជាតិជប៉ុនជាច្រើនផងដែរ។

កម្មវិធីប្រគល់គ្រឿងឥស្សរិយយសព្រះចៅអធិរាជជប៉ុនជាផ្លូវការ ចំពោះលោក **គង់ ខន** នឹងត្រូវរៀបចំឡើងនៅស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជានាថ្ងៃអនាគតខាងមុខនេះ។